ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃចន្ទ ៧ រោច ខែ កត្តិក ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣*

*រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៩*

# សេចក្តីជូនដំណឹងសម្រាប់សារព័ត៌មានស្តីពី
# ជំនួបពិភាក្សាការងាររវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាមួយនិង
# ឯកឧត្តម Christian Berger ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋអាល្លឺម៉ង់ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

នារសៀលថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៩, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានទទួលជួបពិភាក្សាការងារជាមួយឯកឧត្តម Christian Berger ឯកអគ្គរដ្ឋទូតថ្មី នៃសាធារណអាល្លឺម៉ង់ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាអំពីការបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានសម្តែងនូវការអបអរសាទរចំពោះឯកឧត្តម Christian Berger ដែលត្រូវបានតែងតាំងជាឯកអគ្គរាជទូតថ្មីរបស់អាល្លឺម៉ង់ប្រចាំនៅកម្ពុជា ហើយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យសង្ឃឹមថា តាមរយៈវត្តមាន និងបេសកកម្មការទូតរបស់ឯកឧត្តមឯកអគ្គរាជទូតថ្មីនៅកម្ពុជា, កិច្ចសហប្រតិបត្តិការទ្វេភាគីរវាងប្រទេសទាំងពីរ កម្ពុជា-អាល្លឺម៉ង់ នឹងត្រូវបានពង្រឹង និងពង្រីកថែមទៀតនៅលើគ្រប់វិស័យ ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានបញ្ជាក់ថា កម្ពុជា និងអាល្លឺម៉ង់ មានប្រវត្តិនៃទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការយូរលង់ណាស់មក ហើយកម្ពុជាថ្លែងអំណរគុណនូវតួនាទីរបស់អាល្លឺម៉ង់នៅក្នុងដំណើរការស្វែងរកសន្តិភាព និងការអភិវឌ្ឍកម្ពុជាចាប់តាំងពីឆ្នាំ ១៩៩២ រហូតមកដល់បច្ចុប្បន្ន ។ ជាក់ស្តែង កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៅប្រទេសកម្ពុជា បានផ្តោតសំខាន់លើវិស័យអាទិភាពចំនួន ០៣ គឺអភិវឌ្ឍន៍ជនបទ, ការគាំពារសង្គម និងអភិបាលកិច្ច ។

ឯកឧត្តម Christian Berger បានវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះការរីកចម្រើន និងផ្លាស់ប្តូរគួរឱ្យកត់សម្គាល់របស់កម្ពុជានាបរិការណ៍បច្ចុប្បន្ន ជាមួយការអភិវឌ្ឍ និងមានសុខសន្តិភាពពេញលេញ ដែលសមិទ្ធផលទាំងនេះ គឺកើតឡើងពីកិច្ចខិតខំប្រឹងប្រែងផ្ទាល់របស់រាជរដ្ឋាភិបាលកម្ពុជាតែម្តង ។ ឯកឧត្តម បានបន្តថា ក្នុងរយៈពេល ២០ឆ្នាំកន្លងមកនេះ កម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ហើយរឹងមាំ ដែលកត្តាទាំងនេះបានធ្វើឱ្យកម្ពុជាផ្លាស់ប្តូរមុខមាត់យ៉ាងលឿនបំផុតលើឆាកអន្តរជាតិ ។ ឈរលើហេតុផលពិតនៃការអភិវឌ្ឍទាំងនេះ, អាល្លឺម៉ង់នឹងជួយគាំទ្រ និងបង្ហាញការពិតពីកិច្ចអភិវឌ្ឍន៍នៅកម្ពុជាបន្តទៀត ដើម្បីជំរុញឱ្យអ្នកវិនិយោគិនអាល្លឺម៉ង់មកបណ្តាក់ទុនវិនិយោគបន្ថែមឱ្យបានកាន់តែច្រើននៅកម្ពុជា ។

ភាគីទាំងពីរ បានសម្តែងនូវការរីករាយ និងវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការហិរញ្ញប្បទានដែលប្រទេសទាំងពីរ ទើបនឹងបញ្ចប់កិច្ចចរចាពាក់ព័ន្ធនឹងវិស័យថាមពល ដោយរដ្ឋាភិបាលអាល្លឺម៉ង់, តាមរយៈធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ (KfW), នឹងផ្តល់ឥណទានសម្បទានលើកទីមួយដល់កម្ពុជា ។ ភាគីទាំងពីរគ្រោងចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទាននេះមុនបំណាច់ឆ្នាំ ២០១៩ នេះ ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ក៏បានជូនពរឯកឧត្តម Christian Berger ឱ្យទទួលបានជោគជ័យក្នុងតួនាទីថ្មីរបស់ឯកឧត្តមនៅកម្ពុជា និងបានគូសបញ្ជាក់ថា កម្ពុជា នឹងបន្តខិតខំលើកកម្ពស់កិច្ចសហប្រតិបត្តិការ និងមិត្តភាពឱ្យកាន់តែស្អិតរមួតបន្ថែមទៀត ដើម្បីជាឧត្តមប្រយោជន៍សម្រាប់ប្រទេស និងប្រជាជននៃប្រទេសទាំងពីរ កម្ពុជា-អាល្លឺម៉ង់ ។